# ព្រះរាជក្រម

នស/រកម/០១០៧/០០៥

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៦ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យធម្មនុញ្ញភាព និងបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមរយៈសេចក្តីសម្រេចលេខ ០៩០/០០១/២០០៧ កបធ.ប ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៧ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
# ស្តីពី
# វិសោធនកម្មច្បាប់ស្តីពីការរៀបចំ
# និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

**មាត្រាតែមួយ.—**

មាត្រា ១ មាត្រា ៣ ដល់មាត្រា ៥ មាត្រា ១២ មាត្រា ១៤ដល់មាត្រា ១៨ មាត្រា ២២ មាត្រា ២៤ មាត្រា ២៥ មាត្រា ២៧ មាត្រា ២៩ មាត្រា ៣០ និងមាត្រា ៣៤ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ត្រូវបានកែប្រែដូចខាងក្រោម:

**មាត្រា ១ .— ថ្មី**

ច្បាប់នេះមានគោលដៅបង្កើត និងកំណត់ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ ពិនិត្យនិងសម្រេចអំពីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

**មាត្រា ៣ .— ថ្មី**

សមាជិកទាំង ៩ រូប នៃក្រុមប្រឹក្សាធម្មនុញ្ញត្រូវជ្រើសរើសក្នុងចំណោមឥស្សរជនដែលមានសញ្ជាតិខ្មែរពីកំណើត មានអាយុយ៉ាងតិច ៤៥ឆ្នាំ មានសញ្ញាប័ត្រចាប់ពីឧត្តមសិក្សាឡើងទៅខាងច្បាប់ ខាងរដ្ឋបាល ខាងការទូត ឬ ខាងសេដ្ឋកិច្ច ហើយដែលមានបទពិសោធន៍ក្នុងការងារយ៉ាងតិច ១៥ ឆ្នាំ ។

10

សមាជិកនៃក្រុមប្រឹក្សាធម្មនុញ្ញ ៣រូប ត្រូវតែងតាំងដោយព្រះមហាក្សត្រ ៣រូប ត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ហើយ៣រូប ទៀតត្រូវជ្រើសតាំងដោយរដ្ឋសភាតាមមតិភាគច្រើនដាច់ខាតនៃសមាជិកនៃរដ្ឋសភាទាំងមូល ។

ការជ្រើសតាំងដោយរដ្ឋសភាអាចធ្វើឡើងជាពីរលើកបាន ។

ក្នុងអាណត្តិទី ១ បើការបោះឆ្នោតលើកទី ១ មិនបានទទួលមតិភាគច្រើនដាច់ខាតនោះ ត្រូវបោះឆ្នោតជាលើកទី ២ ដោយយកអ្នកដែលបានទទួលសំឡេងច្រើនជាងគេចំនួនយ៉ាងច្រើន ៥រូប មកបោះឆ្នោតឡើងវិញ ។ ការបោះឆ្នោតលើកទី ២ នេះ ត្រូវយកតាមមតិភាគច្រើនដោយប្រៀប ។ អ្នកដែលទទួលបានសំឡេងច្រើនជាងគេត្រូវតែងតាំងសម្រាប់ ៩ ឆ្នាំ អ្នកដែលទទួលបានសំឡេងបន្ទាប់ត្រូវតែងតាំងសម្រាប់ ៦ឆ្នាំ និងអ្នកដែលទទួលបានសំឡេងបន្ទាប់មកទៀតត្រូវតែងតាំងសម្រាប់ ៣ឆ្នាំ ។

ក្នុងអាណត្តិបន្តបន្ទាប់ បើការបោះឆ្នោតលើកទី ១ មិនបានទទួលមតិភាគច្រើនដាច់ខាតនោះ ត្រូវបោះឆ្នោតជាលើកទី ២ ដោយយកអ្នកដែលបានទទួលសំឡេងច្រើនជាងគេចំនួន ២រូប មកបោះឆ្នោតឡើងវិញ ។ ការបោះឆ្នោតលើកទី ២ នេះ ត្រូវយកតាមមតិភាគច្រើនដោយប្រៀប ។

ក្នុងករណីដែលបេក្ខជនទទួលបានសំឡេងស្មើគ្នានោះ ត្រូវយកអ្នកដែលមានអាយុច្រើនជាងគេ ។

បេក្ខជនម្នាក់ៗដែលនឹងត្រូវជ្រើសតាំងដោយរដ្ឋសភា ត្រូវមានហត្ថលេខាគាំទ្រជាមុនពីសមាជិករដ្ឋសភាចំនួនមួយភាគដប់នៃសមាជិកទាំងមូល ។ សមាជិករដ្ឋសភា ១រូប មានសិទ្ធិគាំទ្របានតែបេក្ខជន ១រូប ប៉ុណ្ណោះ ។

**មាត្រា ៤ .- ថ្មី**

ក្នុងរយៈពេលបីឆ្នាំម្តង បីឆ្នាំម្តង សមាជិកចំនួន ៣រូប ត្រូវផ្លាស់ប្តូរនិងតែងតាំងជាថ្មី គឺ ១រូបតែងតាំងដោយព្រះមហាក្សត្រ ១រូបតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និង ១រូបទៀតជ្រើសតាំងដោយរដ្ឋសភា ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវបានជ្រើសតាំងតាមការបោះឆ្នោតដោយសមាជិកក្រុមប្រឹក្សាធម្មនុញ្ញរៀងរាល់ ៣ឆ្នាំម្តង តាមមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូល ក្រោយពីសមាជិក ៣រូប ចូលកាន់តំណែង ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញចាស់អាចត្រូវជ្រើសតាំងជាថ្មីបាន ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញមានឋានៈ និងបុព្វសិទ្ធិស្មើនឹងប្រធានរដ្ឋសភា ។

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមានឋានៈ និងបុព្វសិទ្ធិស្មើនឹងអនុប្រធានរដ្ឋសភា ។

អតីតសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ទទួលប្រាក់សោធននិវត្តន៍ប្រចាំខែស្របតាមលក្ខ-ខណ្ឌ និងរូបមន្តសម្រាប់គណនារៀបចំរបបសោធននិវត្តន៍របស់អតីតតំណាងរាស្ត្រ ។

## មាត្រា ៥ .– ថ្មី

មុខងារសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានវិសមិតភាពជាមួយនឹងមុខងារជាសមាជិករាជរដ្ឋាភិបាល សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា ប្រធាន អនុប្រធានគណបក្សនយោ-បាយ ប្រធាន អនុប្រធានសហជីព និងចៅក្រមក្នុងតំណែង ។

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមិនត្រូវបំពេញមុខតំណែង និងមុខរបរផ្សេងទៀតនៅក្នុងអាណត្តិរបស់ខ្លួនឡើយ ។

អ្នកដែលបានតែងតាំងជាសមាជិកនៃក្រុមប្រឹក្សាធម្មនុញ្ញ មុនចូលកាន់តំណែង ត្រូវសុំលាឈប់ជាបណ្តោះអាសន្នពីតំណែង ឬ មុខរបរទាំងអស់ដែលបានចែងក្នុងវាក្យខ័ណ្ឌខាងលើ ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅសមាជិក ដែលនៅក្នុងមុខតំណែងនិងមុខរបរខាងលើ ឱ្យសុំលាឈប់ពីតំណែង ឬ មុខរបរនោះជាបន្ទាន់ ។

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញត្រូវសុំដកខ្លួនចេញពីរឿងទាំងឡាយណាដែលផលប្រយោជន៍ផ្ទាល់ខ្លួនពាក់ព័ន្ធក្នុងរឿងនោះ ។ ការសុំដកខ្លួនឬការតម្រូវឱ្យដកខ្លួន ត្រូវសម្រេចដោយក្រុមប្រឹក្សាធម្មនុញ្ញ តាមមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងមូល ។

## មាត្រា ១២ .– ថ្មី

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។ ⁂